**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្តល់ទីតាំងដល់សាធារណជនដើម្បីរៀបចំប្រមូលសម្ភារៈ សម្រាប់ជួយដល់វីរកងទ័ពជួរមុខ និងបងប្អូនប្រជាជនភៀសសឹក

ដោយសង្កេតឃើញនូវចលនាសាមគ្គីជាតិយ៉ាងច្រើនកុះកររបស់សាធារណជន ជាពិសេស យុវជនកម្ពុជាយើង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេស យុជន ដែលកំពុងស្វែងរកទីតាំងសម្រាប់រៀបចំប្រមូលសម្ភារៈ ដើម្បីទទួលជំនួយសប្បុរសធម៌សម្រាប់គាំទ្រដល់ដល់វីរកងទ័ពជួរមុខ និងបងប្អូនប្រជាជនភៀសសឹកដែលរងគ្រោះដោយសារសង្គ្រាមឈ្លានពានដ៏ឃោរឃៅពីសំណាក់យោធាថៃ ជ្រាបថា ក្រសួងមានផ្តល់ជូនទីតាំងសម្រាប់រៀបចំចំនួន ២កន្លែង រួមមាន៖

១. សហសាលប្រជុំនៃអគារអង្គរវត្ត ក្នុងបរិវេណវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) មានអាសយដ្ឋាន មហាវិថីសហព័ន្ធរុស្ស៊ី ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២. បរិវេណវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) មានអាសយដ្ឋាន ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់ក្រុមការងារ « **ខ្មែរតែមួយ បេះដូងតែមួយ** » **(ONE HEART TEAM)** តាមរយៈទូរសព្ទលេខ ០១៧ ៩៨៥ ៨៧៧/០៦៦ ២០៣ ៦៨៩/ ០៩៧ ៣៧៣ ៨២៣៣ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសយុវជន ជ្រាបជាព័ត៌មាន។

ថ្ងៃអាទិត្យ ៩រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥

**ទីតាំង វិទ្យាស្ថាន (NTTI)** **ទីតាំង វិទ្យាស្ថាន (NPIC)**